# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ខ្មែរគប្បីអនុវត្តប្រជាធិបតេយ្យសេរីពហុបក្សឲ្យបានត្រឹមត្រូវ ។

website ៖ www.hoksavann.org

*ថ្ងៃទី៣ សីហា ២០០៩*



*លោកមៀក-ម៉ារិន ជាគ្រូបង្រៀនមធ្យមសិក្សា ហើយជានាយកការិយាល័យបុគ្គលិកនៃទីចាត់ការមធ្យមសិក្សាភ្នំពេញឆ្នាំ១៩៦៨ដល់ឆ្នាំ១៩៧៥ បានផ្ញើអ៊ីមែលមកយើង ជាមួយឯកសារដ៏មានខ្លឹមសារ អំពីព្រឹត្តិការណ៍ខ្មែរ ហើយគាត់បបួលជនជាតិខ្មែរឲ្យគោរពព្រះពុទ្ធសាសនាឲ្យបានម៉ឺងម៉ាត់ ដើម្បីសុខសន្តិភាពនិងវឌ្ឍនភាពនៃប្រទេសកម្ពុជា ។ ឧត្តមគតិរបស់លោកមៀក-ម៉ារិននេះ ជាឧត្តមគតិត្រឹមត្រូវ ព្រោះព្រះពុទ្ធសាសនាជាមាគ៌ាបរិសុទ្ធ អាចញ៉ាំងឲ្យសង្គមខ្មែរដែលប្រតិបត្តិតាមបានសុខសន្តិភាព ។ ប៉ុន្តែព្រឹត្តិការណ៍ដែលធ្វើឲ្យខ្មែររងទុក្ខវេទនានេះ ដោយសារអ្នកនយោបាយខ្មែរមិនគោរពតាមព្រះពុទ្ធសាសនានេះឯង ។ តទៅនេះយើងសូមវិភាគអំពីរបបគ្រប់គ្រងរបស់អ្នកនយោបាយខ្មែរ តើគោរពតាមព្រះពុទ្ធសាសនាឬទេ ? ហើយរបបគ្រប់គ្រងសព្វថ្ងៃនេះ គោរពតាមរដ្ឋធម្មនុញ្ញដែលចែងថា ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្សបានត្រឹមត្រូវឬទេ ? ។*

*ជនជាតិខ្មែរបានឆ្លងកាត់របបរាជានិយម របបសាធារណរដ្ឋ របបកុម្មុយនិស្ត ។ របបទាំងនេះមានការខុសឆ្គងបែបណា មានកង្វះខាតអ្វី បានជាធ្វើឲ្យជនជាតិខ្មែររងទុក្ខវេទនា ស្លាប់ព្រាត់ប្រាសគ្នាដោយសារចំបាំងបង្ហូរឈាមរវាងបងប្អូនខ្មែរគ្នាឯងនេះ ។*

យើងគួរពិនិត្យមើលរបបពីរ គឺរបបសង្គមរាស្ត្រនិយម និងរបបប្រជាធិបតេយ្យសេរីពហុបក្ស គឺរបបកំពុងប្រព្រឹត្តទៅសព្វថ្ងៃនេះ ។ យើងមិននិយាយអំពីរបបសាធារណរដ្ឋខ្មែរក្នុងទីនេះទេ ព្រោះរបបនេះកើតឡើងក្នុងសម័យសង្គ្រាម ពុំអាចធ្វើអ្វីឲ្យបានប្រាកដឡើយ ។ ឯរបបឃាតករខ្មែរក្រហម ក៏មិននិយាយក្នុងទីនេះដែរ ។

## របបសង្គមរាស្ត្រនិយម

របបសង្គមរាស្ត្រនិយមបានបង្កើតឡើងដោយសម្តេចនរោត្តម-សីហនុ បន្ទាប់ពីព្រះអង្គដាក់រាជ្យនៅឆ្នាំ១៩៥៥ ។ របបនេះបានបើកឲ្យគណបក្សដទៃប្រណាំងប្រជែងដែរ ដូចគណបក្សប្រជាធិបតេយ្យជាដើម ។ ច្បាប់បង្កើតឲ្យមានគណបក្សច្រើន ប៉ុន្តែការអនុវត្តន៍របស់គណបក្សដទៃ ក្រៅពីសង្គមរាស្ត្រនិយម មានការពិបាកក្នុងការអនុវត្តន៍ ដោយឆ្លងកាត់ឧបសគ្គជាច្រើន ដោយប៉ូលិសជាតិចេះតែទៅឆាឆៅធ្វើឲ្យរំខាន គំរាមកំហែងឲ្យចូលគណបក្សសង្គមរាស្ត្រនិយមវិញ ។ របូតចោលគ្រាប់បែកទៅក្នុងទីស្នាក់ការគណបក្សប្រជាធិបតេយ្យ បណ្តាលឲ្យលោកអៀវ-កើសជាអគ្គលេខាធិការនៃគណបក្សនេះបានត្រូវស្លាប់ ។ អំពើគួរឲ្យរន្ធត់នេះ បានធ្វើឲ្យសមាជិកនៃគណបក្សដទៃៗទៀត រួមទាំងគណបក្សប្រជាធិបតេយ្យមានការភ័យខ្លាច ។ ដើម្បីយកសុខ សមាជិកខ្លះបានលាឈប់ សមាជិកខ្លះបានរត់ទៅចូលគណបក្សសង្គមរាស្ត្រនិយមតែម្តង ។ គណបក្សក៏ត្រូវរលាយ ហើយគ្មានគណបក្សបង្កើតថ្មីទៀតទេ ។ សូម្បីសារពត៌មានរបស់គណបក្សក៏ត្រូវបិទ មិនហ៊ានផ្សាយតទៅទៀតឡើយ ។ ដូ-ច្នេះរាជាណាចក្រកម្ពុជាពេលនោះមានតែគណបក្សមួយ គឺសង្គមរាស្ត្រនិយម ដែលមានសម្តេចនរោត្តម-សីហនុជាប្រធាន ។ តើរបបដែលមានគណបក្សតែមួយដូចរបបកុម្មុយនិស្ត តើធ្វើឲ្យប្រទេសកម្ពុជាមានសន្តិភាព និងលូតលាស់ចំរើនឬទេ ? ក្រោយមកយើងឃើញបង្កើតរដ្ឋាភិបាលសំណាងចុងក្រោយ និងរដ្ឋាភិបាលស្រោចស្រង់ជាតិ នេះបញ្ជាក់ថា សេដ្ឋកិច្ចបានចុះដុនដាប ហើយភ្នាក់ងារយៀកកុង-យៀកណាមខាងជើងបានមកនៅក្នុងជាសម្ងាត់ពាសពេញប្រទេសកម្ពុជា ។ ទីបំផុត កើតព្រឹត្តិការណ៍១៨មីនា១៩៧០ ទម្លាក់សម្តេចនរោត្តម-សីហនុ ទោះបីទម្លាក់ក្នុងរូបភាពរដ្ឋប្រហារក្តី ស្របច្បាប់ក្តី ។ អ្នកដែល

ទម្លាក់គឺលោកលន់-នល់ ជាកូនចៅសម្ដេចដែលសម្ដេចឲ្យបុណ្យស័ក្តិ ។ សូម្បីលោកអ៊ិន-តាំដែលធ្លាប់និយាយថា សូមហែតាមសម្ដេចរហូតដំណាក់ឈាមជាចុងក្រោយ ក៏រួមក្បត់ទម្លាក់សម្ដេចដែរ ។ នេះបង្ហាញថា ការប្រមូលមនុស្សឲ្យមានតែគណបក្សតែមួយ គឺសង្គមរាស្ត្រនិយម ស្មានថារស់សត្រូវហើយ ផ្ទុយទៅវិញ សត្រូវមកកាន់តែកៀកខ្លួនទៅវិញ ។ លទ្ធិប្រជាធិបតេយ្យគ្មានទេ បើគ្មានគណបក្សប្រឆាំង ។ តានក្បួនសេដ្ឋកិច្ចក៏ដូចជានយោបាយ បើគ្មានការប្រណាំងប្រជែងគ្នាទេ មិនអាចធ្វើឲ្យប្រទេសលូតលាស់ចំរើនឡើយ ។ អ្នកដែលសុខចិត្តចូលមករួម ជាការការពារសន្តិសុខផ្ទាល់ខ្លួនដោយការបង្ខំចិត្ត គេរង់ចាំឱកាសណាមួយ ពួកគេនឹងក្រោកឡើង ។ យើងលើកយករបបសង្គមរាស្ត្រនិយមមកបង្ហាញយ៉ាងសង្ខេបនេះ ជាមេរៀនឆ្លុះបញ្ចាំងមើលគណបក្សប្រជាជនកម្ពុជា ដែលសព្វថ្ងៃកំពុងកាន់អំណាច តើមានលក្ខណៈដូចគ្នានឹងរបបសង្គមរាស្ត្រនិយមឬទេ ?

## គណបក្សប្រជាជនកម្ពុជា

គណបក្សប្រជាជនកម្ពុជានេះលេចមុខឡើងនៅពេលដែលកងទ័ពយួនចូលមកប្រទេសកម្ពុជា ដេញពួកខ្មែរក្រហមចេញពីអំណាច ហើយតែងតាំងគណបក្សប្រជាជននេះឲ្យឡើងកាន់អំណាចជំនួស ។ ដោយអនុវត្តតាមកិច្ចព្រមព្រៀងអន្តរជាតិនៅទីក្រុងប៉ារីសប្រទេសបារាំងឆ្នាំ១៩៩១ ដើម្បីសន្តិភាពប្រទេសកម្ពុជា នៅឆ្នាំ១៩៩៣មានការបោះឆ្នោតនៅប្រទេសកម្ពុជា ក្រោមច្បាប់រដ្ឋធម្មនុញ្ញប្រជាធិបតេយ្យសេរីពហុបក្ស ។ ការបោះឆ្នោតនោះមានអង្គការសហប្រជាជាតិជាអ្នកចាត់ចែង ។ គណបក្សហ៊្វុនស៊ិនប៉ិចរបស់សម្ដេចនរោត្តមសីហនុ មានប្រៀបជាងគណបក្សប្រជាជនកម្ពុជា ។ ប៉ុន្តែដោយគណបក្សហ៊្វុនស៊ិនប៉ិចមិនចេះធ្វើការ ចាញ់ល្បិចគណបក្សប្រជាជនកម្ពុជា គណបក្សនេះបានត្រូវចុះខ្សោយរាល់អាណត្តិ ហើយសព្វថ្ងៃក៏ត្រូវរលាយខ្លួន ។

តាមការសង្កេត ចំពោះគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា គណបក្សប្រជាជនកម្ពុជាបានយកលោកអៀង-មូលីជាជើងអុកប្រឆាំងនឹងលោកសឺន-សាន ដែលទាំងពីរនាក់ជាគណបក្សជាមួយគ្នា គឺគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ដែលពីដើមជារណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។ ដោយឥទ្ធិពលខាងក្រៅ គណបក្សនេះក៏បែកបាក់គ្នា រហូតដល់រលា

យខ្លួនទាំងស្រុង ។ ក្រោយមកទៀត គណបក្សប្រជាជនកម្ពុជាបានទាញយកលោកញឹក-ប៊ុនឆៃជាជើងអុកឲ្យប្រឆាំងនឹងទ្រង់រណឫទ្ធិ ហើយគណបក្សហ្វ៊ុនស៊ិនប៉ិចក៏ត្រូវបែកគ្នាជាពីរ ហើយសព្វថ្ងៃក៏រលាយខ្លួនដែរ ។ គណបក្សប្រឆាំងមួយទៀត គឺគណបក្សសម-រង្ស៊ី ក៏ត្រូវទទួលរងគ្រោះយ៉ាងធ្ងន់ មានសមាជិករបស់ខ្លួនត្រូវស្លាប់និងត្រូវរបួសជាច្រើន ដោយឧក្រិដ្ឋជនបោកគ្រាប់បែកក្នុងឱកាសធ្វើបាតុកម្មអហឹង្សាមួយ ។ សមាជិកខ្លះត្រូវចោទអំពីបទបរិហារកេរ្តិ៍ ។ សូម្បីតែអ្នកសរសេរសារពត៌មានគាំទ្រគណបក្សប្រឆាំងនេះ ក៏ត្រូវគេលួចបាញ់សម្លាប់ ខ្លះត្រូវជាប់គុក ខ្លះត្រូវរត់ចោលស្រុក ខ្លះសុំចុះចូលគណបក្សប្រជាជនដើម្បីសន្តិសុខ ។

តើគណបក្សប្រជាជនចង់ធ្វើដូចគណបក្សសង្គមរាស្ត្រនិយម គឺបង្កើតរបបដឹកនាំប្រទេសកម្ពុជាមានគណបក្សតែមួយ គឺគណបក្សប្រជាជនកម្ពុជា ដែលផ្ទុយអំពីរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ដែលចែងនៅក្នុងមាត្រាទី៥១ថា «ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស» ប៉ុន្តែយើងយល់ថា គណបក្សប្រជាជនមិនល្ងង់របូតធ្វើឲ្យរបបដឹកនាំប្រទេសកម្ពុជាមានគណបក្សតែមួយឡើយ ។ ព្រោះអ្វី ? ព្រោះថា គណបក្សនេះចង់បង្ហាញឲ្យពិភពលោកមើលឃើញថា ប្រទេសកម្ពុជាសព្វថ្ងៃកាន់របបប្រជាធិបតេយ្យសេរី មានគណបក្សច្រើន ដើម្បីឲ្យស្របតាមរដ្ឋធម្មនុញ្ញផង និងឲ្យពិភពលោកគាំទ្រនិងបានជំនួយកសាងប្រទេសកម្ពុជាតទៅទៀត ។ ប៉ុន្តែគណបក្សប្រជាជនកម្ពុជាប្រើមធ្យោបាយគ្រប់យ៉ាងចំពោះគណបក្សដទៃទៀត មិនឲ្យមានកម្លាំងស្មើ ឬលើសពីគណបក្សរបស់ខ្លួនឡើយ ។ បានសេចក្តីថា ការមានគណបក្សប្រឆាំង គ្រាន់តែលំអឲ្យគណបក្សប្រជាជនប៉ុណ្ណោះ ។

## <u>សេចក្តីសន្និដ្ឋាន</u>

តាមឧត្តមគតិព្រះពុទ្ធសាសនាចែងថា គុណសម្បត្តិរបស់មនុស្សខ្ពង់ខ្ពស់ថ្លៃថ្នូរ គឺស្ថិតនៅលើអំពើដែលគេកសាងល្អ ដោយកាយ វាចា និងចិត្ត មិនបៀតបៀនអ្នកដទៃ ។ យ៉ាងណាមិញ ប្រទេសកម្ពុជាដើម្បីឲ្យមានមុខមាត់ល្អក្នុងឆាកអន្តរជាតិ និងដើម្បីឲ្យខ្មែរនិងខ្មែររស់នៅជាមួយគ្នាបានសុខសាន្ត ត្រូវតែនាំគ្នាកសាងអំពើល្អ កុំបៀតបៀនគ្នា ទោះបីបញ្ហាធម្មតាក្តី បញ្ហានយោបាយក្តី ។

ដោយមើលឃើញខ្មែររងទុក្ខវេទនាជាច្រើនទសវត្សរ៍ ជាពិសេសសម័យវាលពិឃាតខ្មែរក្រហម បានជាអង្គការសហប្រជាជាតិ ក្រោមកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសប្រទេសបារាំងឆ្នាំ១៩៩១ តម្រូវឲ្យខ្មែររួបរួមគ្នាដោះស្រាយបញ្ហាជាតិខ្លួនដោយសន្តិវិធី ដោយជ្រើសរើសអ្នកដឹកនាំ តាមរយៈការបោះឆ្នោតប្រកបដោយសេរីនិងយុត្តិធម៌ តាមរបបប្រជាធិបតេយ្យសេរីពហុបក្ស ។ គោលការណ៍នេះល្អត្រឹមត្រូវ តាមឧត្តមគតិព្រះពុទ្ធសាសនា ហើយគួរគ្រប់គណបក្សខ្មែរអនុវត្តឲ្យបានត្រឹមត្រូវ ត្រូវប្រណាំងប្រជែងគ្នាតាមច្បាប់ កុំប្រើហឹង្សាលួចសម្លាប់គ្នា កុំប្រើតុលាការជាឧបករណ៍សំរាប់កំចាត់គ្នា ។ សិទ្ធិបញ្ចេញមតិដោយសេរី និងសិទ្ធិធ្វើនយោបាយជាគោលការណ៍សំខាន់ ដែលគេតែងយកមកប្រើ ដើម្បីឲ្យពលរដ្ឋអស់ចិត្ត មិនចងគំនុំ មិនរត់ចូលព្រៃ ប្រឆាំងនឹងអ្នកកាន់អំណាច ។ អ្នកកាន់អំណាចត្រូវទទួលស្គាល់គណបក្សប្រឆាំង ទុកជាដៃគូនៃការអភិវឌ្ឍន៍ប្រទេស កុំទុកជាគូសត្រូវ ។ ប្រទេសប្រជាធិបតេយ្យ គេគ្រោងថវិកាទុកខ្លះសំរាប់ផ្តល់ជូនគណបក្សធំៗ សំរាប់ចាយវាយក្នុងការឃោសនាបោះឆ្នោតផង ។ អន្តរជាតិគេឲ្យយោបល់ថា គណបក្សនយោបាយខ្មែរតូចៗគួរតែរួបរួមគ្នាធ្វើឲ្យគណបក្សមានចំនួនតិចតែមានទំហំធំ ដើម្បីប្រណាំងប្រជែងគ្នាយកសន្លឹកឆ្នោត ។ នៅសហរដ្ឋអាមេរិក គណបក្សធំមានតែពីរ នៅប្រទេសកាណាដា គណបក្សធំមានតែបួនប៉ុណ្ណោះ ។ អ្នកនយោបាយខ្មែរ គួរអាណិតអាសូរដល់ពលរដ្ឋខ្មែរ ដែលរងទុក្ខវេទនាអស់ពេលជាយូរហើយ កុំបង្កើតទុក្ខដល់ពលរដ្ឋខ្មែរតទៅទៀត ។ ពេលនេះត្រូវតែរួបរួមគ្នាការពារឯករាជ្យ អធិបតេយ្យជាតិ និងបូរណភាពទឹកដីចំពោះមុខសៀមយួន ដែលកំពុងចង់បានទឹកដីខ្មែរតទៅទៀតនេះ ។

ការទាញយករបបនយោបាយខ្មែរមកបញ្ជាក់ប៉ុណ្ណោះ បង្ហាញថាអ្នកនយោបាយខ្មែរមិនដើរតាមព្រះពុទ្ធសាសនាឡើយ ព្រោះមានការបៀតបៀនកាប់សម្លាប់គ្នា ហើយរបបកាន់អំណាចសព្វថ្ងៃនេះ ក៏មិនបានអនុវត្តតាមកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសឆ្នាំ១៩៩១ និងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ឲ្យបានពេញលេញឡើយ ។៚